Cancer Council SA

# រោគរលាកថ្លើមជំពូក B និងជំងឺមហារីកថ្លើម

**សន្លឹកព័ត៌មាននេះស្តីអំពីវ៉ាយរ៉ុសនៃរោគរលាកថ្លើមជំពូក B និងទំនាក់ទំនងរបស់វាជាមួយជំងឺមហារីកថ្លើម។**

**ជនជាតិអូស្ត្រាលីច្រើនជាង 210,000 នាក់មានរោគរលាកថ្លើមជំពូក B រ៉ាំរ៉ៃ។ មនុស្សជាច្រើនពុំដឹងខ្លួនថាគេមានរោគនេះឡើយ ហើយប្រហែលជាប្រឈមមុខនឹងគ្រោះថ្នាក់នៃជំងឺមហារីកថ្លើមទៀតផង។**

## តើរោគរលាកថ្លើមជំពូក B ជាអ្វី?

រោគរលាកថ្លើមជំពូកB ឬ ‘Hep B’ គឺជាវ៉ាយរ៉ុស។ វាប៉ះពាល់ដល់ថ្លើម។

វាអាចបណ្ដាលឲ្យមានៈ
- ការរលាក (ការហើម)
- ស្លាកស្នាម (ត្រូវបានគេស្គាល់ដែរថាជារោគក្រិនថ្លើម) និង/ឬ
- ជំងឺមហារីកថ្លើម។

## តើរោគរលាកថ្លើមជំពូក B រ៉ាំរ៉ៃមានន័យដូចម្ដេច?

មនុស្សដែលមានរោគរលាកថ្លើមជំពូក B ច្រើនជាង 6 ខែមានរោគរលាកថ្លើមជំពូក B 'រ៉ាំរ៉ៃ'។ មនុស្សភាគច្រើនអាចមានជំងឺនេះនៅពេលគេនៅទារក ឬក្មេងតូច។ អស់អ្នកដែលមានរោគរលាកថ្លើមជំពូក B រ៉ាំរ៉ៃអាចមានអារម្មណ៍ស្រួលខ្លួនធម្មតា។ គេប្រហែលជាពុំមានសញ្ញាណាមួយនៃរោគឆ្លងនេះឡើយ។ ទោះជាយ៉ាងនេះក្ដី មនុស្សមួយចំនួននឹងមានស្លាកស្នាមក្នុងថ្លើម និង/ឬកើតជំងឺមហារីកថ្លើម។

## តើលោកអ្នកកើតរោគរលាកថ្លើមជំពូក B តាមរបៀបណា?

វ៉ាយរ៉ុសនៃរោគរលាកថ្លើមជំពូក B ត្រូវបានផ្ទុកក្នុងវត្ថុរាវនៃរាងកាយ និងក្នុងឈាម។ វ៉ាយរ៉ុសនេះឆ្លងរាលដាលនៅពេលវត្ថុរាវទាំងនេះចូលទៅក្នុងរាងកាយរបស់មនុស្សណាម្នាក់ទៀត។

វ៉ាយរ៉ុសនេះអាចឆ្លងរាលដាលៈ
- ពីម្ដាយទៅកូនក្នុងអំឡុងពេលមានផ្ទៃពោះ ឬពេលសម្រាលកូន (ប្រសិនបើទារកពុំបានចាក់ថ្នាំបង្ការរោគនៅពេលកើតមក)
- តាមរយៈការរួមភេទដែលគ្មានការការពារ
- ដោយការប្រើគ្រឿងប្រដាប់ចាក់ថ្នាំរួមគ្នា
- ដោយដំណើរការផ្នែកពេទ្យដែលពុំបានសំអាតសម្លាប់មេរោគ
- ដោយចាក់បញ្ចូលឈាមចូលទៅក្នុងចរន្តឈាមតាមរបៀបដទៃទៀត។

ជំងឺនេះមិនអាចឆ្លងរាលដាលដោយៈ
- ញ៉ាំអាហារ ភេសជ្ជៈ និងប្រើប្រាស់សមស្លាបព្រាកាំបិតរួមគ្នា
- ការឱប និងថើប
- ការចាប់ដៃស្វាគមន៍។

## តើលោកអ្នកដឹងថាលោកអ្នកមានរោគរលាកថ្លើមជំពូក B រ៉ាំរ៉ៃតាមរបៀបណា?

ស្នើសុំឲ្យវេជ្ជបណ្ឌិតរបស់លោកអ្នកធ្វើតេស្តឈាមរកមើលរោគរលាកថ្លើមជំពូក B។ ការធ្វើតេស្តឈាមអាចប្រាប់ឲ្យលោកអ្នកដឹង ប្រសិនបើលោកអ្នកៈ
- មានរោគរលាកថ្លើមជំពូក B រ៉ាំរ៉ៃ
- ត្រូវការការចាក់ថ្នាំបង្ការរោគដើម្បីការពារលោកអ្នក
- ធ្លាប់បានចាក់ថ្នាំបង្ការរោគពីពេលមុន ហើយត្រូវបានការពារ។

មនុស្សម្នាក់ក្នុងចំណោមមនុស្ស 3 នាក់ដែលមានរោគរលាកថ្លើមជំពូក B រ៉ាំរ៉ៃក្នុងប្រទេសអូស្ត្រាលីពុំដឹងខ្លួនថាគេមានរោគនេះឡើយ។ មនុស្សជាច្រើនពុំបានបង្ហាញឲ្យឃើញសញ្ញាណាមួយនៃរោគនេះឡើយ។ ប្រសិនបើលោកអ្នកពុំមានរោគរលាកថ្លើមជំពូក B ទេ ការចាក់ថ្នាំបង្ការរោគនឹងការពារលោកអ្នកទប់ទល់នឹងការឆ្លងរោគរលាកថ្លើមជំពូក B។

## តើនរណាខ្លះគួរធ្វើតេស្តរកមើលរោគរលាកថ្លើមជំពូក B?

1. មនុស្សដែលបានកើតនៅតំបន់អាស៊ីប៉ាស៊ីហ្វិកទ្វីបអាហ្វ្រិក អាមេរិកកណ្ដាល និងអាមេរិកខាងត្បូងតំបន់អឺរ៉ុបខាងកើត និងខាងត្បូង តំបន់ការ៉ាប៊ីន និងមជ្ឈឹមបូព៌ា។ ការពិនិត្យសុខភាពដែលលោកអ្នកត្រូវការដើម្បីធ្វើអន្តោប្រវេសន៍មកកាន់ប្រទេសអូស្ត្រាលី តាមធម្មតាពុំធ្វើតេស្តរកមើលរោគរលាកថ្លើមជំពូក B ឡើយ។
2. ប្រជាជនអាបូរីជីនី និងអ្នករស់នៅលើកោះ Torres Strait។

## តើមានទំនាក់ទំនងអ្វីខ្លះរវាងរោគរលាកថ្លើមជំពូក B និងជំងឺមហារីកថ្លើម?

វ៉ាយរ៉ុសនៃរោគរលាកថ្លើមជំពូក B អាចបណ្ដាលឲ្យកើតជំងឺមហារីកថ្លើម។ ជំងឺមហារីកថ្លើមគឺជាដុំសាច់ដែលដុះលូតលាស់ក្នុងថ្លើម។ មនុស្សដែលមាន ឬគ្មានរោគក្រិនថ្លើមអាចកើតជំងឺមហារីក។ មានដល់ទៅមនុស្សម្នាក់ក្នុងចំណោមមនុស្ស 4 នាក់ដែលមានរោគរលាកថ្លើមជំពូក B រ៉ាំរ៉ៃ នឹងកើតរោគក្រិនថ្លើម និង/ឬជំងឺមហារីកថ្លើម។

## តើនរណាខ្លះប្រឈមមុខនឹងគ្រោះថ្នាក់នៃការកើតជំងឺមហារីកថ្លើមទាក់ទិននឹងរោគរលាកថ្លើមជំពូក B?

អ្នកណាក៏ដោយដែលមានរោគរលាកថ្លើមជំពូក B រ៉ាំរ៉ៃអាចកើតជំងឺមហារីកថ្លើម។ គេពុំដែលឃើញអ្នកមានផ្ទុកមេរោគរលាកថ្លើមមានសុខភាពល្អឡើយ។ មនុស្សគ្រប់រូបដែលមានរោគរលាកថ្លើមជំពូក B រ៉ាំរ៉ៃ ត្រូវការចាំបាច់ពិនិត្យមើលរោគឲ្យបានទៀងទាត់។

## តើការពិនិត្យមើលរោគនេះនឹងទាក់ទិនអ្វីខ្លះ?

ជាគំនិតល្អដែលវេជ្ជបណ្ឌិតរបស់លោកអ្នកត្រូវបញ្ជូនលោកអ្នកទៅជួបគ្រូពេទ្យឯកទេស។ គ្រូពេទ្យឯកទេសនឹងអាច[2] ផ្ដល់ឱវាទជូនលោកអ្នកអំពីរោគរលាកថ្លើមជំពូក B រ៉ាំរ៉ៃ។

តាមធម្មតា មនុស្សដែលមានរោគរលាកថ្លើមជំពូក B រ៉ាំរ៉ៃ នឹងមានការធ្វើតេស្តឈាមរៀងរាល់ 6 ខែម្តង។ ការធ្វើតេស្តនេះគឺដើម្បីឲ្យដឹងអំពីរបៀបដែលថ្លើមរបស់គេកំពុងមានដំណើរការ។

ប្រសិនបើគ្រូពេទ្យឯកទេសរបស់លោកអ្នក ចង់ធ្វើការពិនិត្យរកមើលច្រើនទៀតអំពីជំងឺមហារីកថ្លើមលោកអ្នកប្រហែលត្រូវធ្វើៈ

- តេស្តឈាមពិនិត្យរកមើលជាតិប្រូតេអ៊ីន AFP រៀងរាល់ 6 ខែម្តង។ AFP គឺជាប្រូតេអ៊ីនដែលកើនឡើង នៅពេលជំងឺមហារីកលូតលាស់។
- តេស្តថតមើលថ្លើមដោយអល់ត្រាសោន (ultrasound) រៀងរាល់ 6 ខែម្តង ដើម្បីពិនិត្យមើលការលូតលាស់ក្នុងថ្លើមរបស់លោកអ្នក។

ការពិនិត្យមើលទាំងនេះ នឹងជួយក្នុងការសម្គាល់ដឹងសញ្ញានៃជំងឺមហារីកថ្លើមឲ្យបានទាន់ពេល នៅពេលវានៅតូច និងងាយស្រួលដើម្បីព្យាបាល។ តាមធម្មតា តេស្តទាំងនេះត្រូវបានធ្វើឡើងសម្រាប់មនុស្សដែលៈ

- មានសាវតាជាជនជាតិអាស៊ី (បុរសអាយុច្រើនជាង 40 ឆ្នាំ និងស្ត្រីអាយុច្រើនជាង 50 ឆ្នាំ)
- មានសាវតាជាជនជាតិអាហ្វ្រិក ហើយមានអាយុច្រើនជាង 20 ឆ្នាំ
- មានប្រវត្តិគ្រួសារកើតជំងឺមហារីកថ្លើម និង/ឬ
- មានស្លាកស្នាមលើថ្លើម(រោគក្រិនថ្លើម)។

## តើមានការព្យាបាលសម្រាប់រោគរលាកថ្លើមជំពូក B រ៉ាំរ៉ៃឬទេ?

មានការព្យាបាលសម្រាប់រោគរលាកថ្លើមជំពូក B រ៉ាំរ៉ៃ។ ការព្យាបាលនេះអាចរក្សាវ៉ាយរ៉ុសឲ្យឋិតនៅក្រោមការគ្រប់គ្រងបាន។ ការព្យាបាលនេះពុំមែនជាការធ្វើឲ្យជាសះស្បើយឡើយ ក៏ប៉ុន្តែអាចជួយការពារកុំឲ្យខូចថ្លើម និងកើតជំងឺមហារីកក្នុងរយៈពេលយូរអង្វែង។

មិនមែនមនុស្សគ្រប់គ្នាដែលមានរោគរលាកថ្លើមជំពូក B រ៉ាំរ៉ៃនឹងត្រូវការការព្យាបាលនោះទេ។ គ្រូពេទ្យឯកទេសនឹងជួយលោកអ្នកសម្រេចចិត្តនៅពេលណាលោកអ្នកត្រូវការការព្យាបាល។

ប្រសិនបើលោកអ្នកមានប័ណ្ណមេឌីឃែរ រដ្ឋាភិបាលអាចបង់ថ្លៃសម្រាប់ការព្យាបាលខ្លះ ឬទាំងអស់សម្រាប់លោកអ្នក។ ប្រសិនបើលោកអ្នកពុំមានប័ណ្ណមេឌីឃែរទេ សូមពិភាក្សាជាមួយគ្រូពេទ្យឯកទេសរបស់លោកអ្នកអំពីអ្វីដែលត្រូវធ្វើ។

## តើមានការព្យាបាលសម្រាប់ជំងឺមហារីកថ្លើមឬទេ?

ការព្យាបាលសម្រាប់ជំងឺមហារីកថ្លើម នឹងអាស្រ័យលើទំហំនៃជំងឺមហារីក ហើយថាតើវាបានឆ្លងរាលដាល ឬអត់។ ជំងឺមហារីកថ្លើមកាន់តែងាយស្រួលព្យាបាលប្រសិនគេរកឃើញវាបានទាន់ពេល។ សូមពិភាក្សាជាមួយគ្រូពេទ្យឯកទេសរបស់លោកអ្នក អំពីជម្រើសនៃការព្យាបាលរបស់លោកអ្នក ។

យើងសូមណែនាំនូវជំហានដូចតទៅនេះ ដើម្បីធ្វើឲ្យភាពប្រឈមមុខនឹងគ្រោះថ្នាក់នៃជំងឺមហារីកថ្លើមទាក់ទិននឹងរោគរលាកថ្លើមជំពូក B របស់លោកអ្នកមានកម្រិតទាបៈ:

- ស្នើសុំធ្វើតេស្តឈាម ដើម្បីពិនិត្យមើលក្រែងលោកអ្នកមានរោគរលាកថ្លើមជំពូក B រ៉ាំរ៉ៃ ជាពិសេសប្រសិនបើលោកអ្នកនៅក្នុងក្រុមមនុស្សដែលមានគ្រោះថ្នាក់កម្រិតខ្ពស់។
- ប្រសិនបើលោកអ្នកមានរោគរលាកថ្លើមជំពូក B រ៉ាំរ៉ៃ សូមស្នើឲ្យវេជ្ជបណ្ឌិតរបស់លោកអ្នកបញ្ជូនលោកអ្នកទៅគ្រូពេទ្យឯកទេសខាងថ្លើម ហើយធ្វើការពិនិត្យមើលឲ្យបានទៀងទាត់។
- ប្រសិនបើលោកអ្នកពុំធ្លាប់បានចាក់ថ្នាំបង្ការរោគរលាកថ្លើមជំពូក B ទេ យើងសូមណែនាំឲ្យលោកអ្នកទទួលការចាក់ថ្នាំ។ ថ្នាំបង្ការរោគនេះនឹងចាក់ជូនដោយឥតគិតថ្លៃសម្រាប់៖
  - គ្រប់ទារកដែលទើបកើត
  - ដៃគូ សមាជិកគ្រួសារ និងអ្នកនៅក្នុងផ្ទះនៃអ្នកកើតរោគរលាកថ្លើមជំពូក B។

## សូមសួរវេជ្ជបណ្ឌិតរបស់លោកអ្នកសម្រាប់ព័ត៌មានបន្ថែម។

លោកអ្នកក៏អាចកាត់បន្ថយគ្រោះថ្នាក់ទាំងមូលនៃជំងឺមហារីកបានដែរដោយៈ

- ផឹកស្រាតែបន្តិចបន្តួច ឬកុំផឹកស្រាទាល់តែសោះ
- បរិភោគផ្លែឈើ និងបន្លែឲ្យបានច្រើន
- កុំបរិភោគខ្លាញ់ច្រើនឬសាច់គេយកមកកែឆ្នៃធ្វើបន្តទៀត
- រក្សាទម្ងន់រាងកាយដែលមានសុខភាពល្អ
- ធ្វើការហាត់ប្រាណឲ្យបានទៀងទាត់ (ចាប់ផ្តើមធ្វើយឺតៗ រួចមកធ្វើកាន់តែច្រើននៅពេលក្រោយៗមក)
- ឈប់ជក់បារី
- ឆែកពិនិត្យរកមើលជំងឺមហារីកកស្បូន មហារីកដោះ និងមហារីកពោះវៀនធំពេលចាំបាច់។

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមទៀតនៅទីណា?

ចំពោះអ្នកដែលប្រឈមនឹងគ្រោះថ្នាក់នៃជំងឺមហារីកថ្លើម ឬអ្នកជំងឺមហារីកថ្លើម អាចបើកមើលគេហទំព័រ **www.cancersa.org.au** ឬទាក់ទងមកក្រុមប្រឹក្សាផ្នែកជំងឺមហារីករដ្ឋវិចតូរីយ៉ា ដោយទូរស័ព្ទលេខ **13 11 20**។ សម្រាប់អ្នកបកប្រែភាសា សូមទូរស័ព្ទលេខ**13 14 50**។

សម្រាប់ព័ត៌មានបន្ថែម និងការផ្តល់ជំនួយផ្នែករោគរលាកថ្លើមជំពូក B សូមបើកមើលគេហទំព័រ **www.hepatitissa.org.au** ឬទូរស័ព្ទមកខ្សែទូរស័ព្ទផ្តល់ព័ត៌មានអំពីរោគរលាកថ្លើមលេខ **1800 437 222**។ សម្រាប់អ្នកបកប្រែភាសា សូមទូរស័ព្ទលេខ **13 14 50**។

សម្រាប់ព័ត៌មានជាភាសាសំខាន់ៗ អំពីរោគរលាកថ្លើមជំពូក B សូមបើកមើលវិបសាយ **www.hepatitissa.org.au**។

Cancer Council 13 11 20
cancersa.org.au

Cancer Council SA
202 Greenhill Road
Eastwood 5063
South Australia
t +61 8 8291 4111
f +61 8 8291 4122
askanurse@cancersa.org.au
**cancersa.org.au**
Cancer Council 13 11 20